Presumptive Eligibility for Pregnant Women
ក្រដាសព័ត៌មានស្តីពីអ្នកមានផ្ទៃពោះ

តើសិទ្ធិចូលរួមសន្ធតជាមុនសម្រាប់ស្ត្រីមានផ្ទៃពោះ [Presumptive Eligibility (PE) for Pregnant Women] នោះគឺជាអ្វី?

PE សម្រាប់ស្ត្រីមានផ្ទៃពោះ គឺការថែទាំសុខភាពបណ្តោះអាសន្នភ្លាម ទាក់ទងនឹងការមានផ្ទៃពោះ សម្រាប់ស្ត្រីមានប្រាក់ចំណូលតិច ។

តើអ្នកណាខ្លះមានសិទ្ធិទទួលអត្ថប្រយោជន៍ PE សម្រាប់ស្ត្រីមានផ្ទៃពោះ ?

ស្ត្រីណាដែលគិតថាខ្លួនមានផ្ទៃពោះ ហើយដែលប្រាក់ចំណូលប្រចាំគ្រួសាររបស់នាងស្ថិតក្រោមកម្រិតកំណត់ គឺមានសិទ្ធិទទួលអត្ថប្រយោជន៍ PE ។ (ឧទាហរណ៍ ពីខែមេសា ឆ្នាំ 2011 ដល់ខែមីនា ឆ្នាំ 2012 កម្រិតប្រាក់ចំណូលគឺ $2452 សម្រាប់គ្រួសារមានពីរនាក់ ដោយស្ត្រីមានផ្ទៃពោះរាប់ជាពីរនាក់ ។) លោកអ្នកត្រូវដាក់ពាក្យតាមរយៈអ្នកផ្តល់សេវាដែលមានសិទ្ធិចូលរួម ។ សូរអ្នកផ្តល់សេវាថែទាំសុខភាពរបស់នាងថា តើគាត់ផ្តល់សេវា PE សម្រាប់ស្ត្រីមានផ្ទៃពោះ ដែរឬទេ ។ អត្ថប្រយោជន៍ចាប់ផ្តើមនៅថ្ងៃដែលនាងទទួលការពិនិត្យលើកដំបូង ។

តើនាងខ្ញុំអាចទទួលអត្ថប្រយោជន៍ PE សម្រាប់ស្ត្រីមានផ្ទៃពោះ យូរប៉ុណ្ណា?

អត្ថប្រយោជន៍ PE សម្រាប់ស្ត្រីមានផ្ទៃពោះ អាចប្រើបាន នៅក្នុងខែដែលនាងដាក់ពាក្យ ហើយនិងមួយខែបន្ទាប់ទៀតដែរ ។ ប័ណ្ណ បញ្ជាក់សិទ្ធិចូលរួមរបស់នាងនឹងមានថ្ងៃផុតកំណត់សរសេរនៅលើវា ។ អត្ថប្រយោជន៍របស់នាងនឹងផុតនៅថ្ងៃនោះ លើកលែងតែនាងដាក់ពាក្យសុំ Medi-Cal ។ នាងត្រូវតែយកភស្តុតាងបញ្ជាក់ពីការដាក់ពាក្យសុំ Medi-Cal ដើម្បីឱ្យអ្នកផ្តល់សេវា PE សម្រាប់ស្ត្រីមានផ្ទៃពោះ បន្តអត្ថប្រយោជន៍របស់នាង ។ នាងត្រូវផ្តល់ភស្តុតាងនោះតែម្តងប៉ុណ្ណោះ ។ អត្ថប្រយោជន៍របស់នាងនឹងត្រូវបានបន្ត រហូតដល់នាងទទួលប័ណ្ណ Medi-Cal ជំរតាមប្រៃសណីយ៍ ឬស្រុកបដិសេធពាក្យសុំរបស់នាង ។

តើអត្ថប្រយោជន៍ PE សម្រាប់ស្ត្រីមានផ្ទៃពោះ ធានារ៉ាប់រងចំពោះការថែទាំសុខភាពអ្វីខ្លះ?

អត្ថប្រយោជន៍ PE សម្រាប់ស្ត្រីមានផ្ទៃពោះ បង់ប្រាក់សម្រាប់ការថែទាំណា ដែលទាក់ទងនឹងផ្ទៃពោះ រួមទាំងការពន្លូតកូន និងការលូតកូន ។ ការពិនិត្យដោយគ្រូពេទ្យ គ្លីនិក និងបន្ទប់អាសន្នភាគច្រើន ត្រូវបានធានារ៉ាប់រង ។ ថ្នាំវីតាមីន និងថ្នាំសម្រាប់ស្ត្រីមានផ្ទៃពោះផ្សេងទៀតភាគច្រើន ត្រូវបានធានារ៉ាប់រង ។ អត្ថប្រយោជន៍ PE សម្រាប់ស្ត្រីមានផ្ទៃពោះ ធានារ៉ាប់រងការពិនិត្យធ្មេញ និងសុខភាពផ្លូវចិត្តខ្លះៗ ដែលទាក់ទងនឹងការមានផ្ទៃពោះ ។ អត្ថប្រយោជន៍ PE សម្រាប់ស្ត្រីមានផ្ទៃពោះ **មិន**ធានារ៉ាប់រងចំពោះការសម្រាលកូននៅក្នុងមន្ទីរពេទ្យ ឬការថែទាំសម្រាកមន្ទីរពេទ្យណាផ្សេងទៀតឡើយ ។

ចុះបើនាងខ្ញុំទទួលសំបុត្រទារថ្លៃសម្រាប់ការថែទាំសុខភាព តើយ៉ាងម៉េចដែរ?

នាងប្រហែលជាទទួលការថែទាំ ដែលមិនធានារ៉ាប់រងដោយអត្ថប្រយោជន៍ PE សម្រាប់ស្ត្រីមានផ្ទៃពោះ ទេ ។ **ចូរដាក់ពាក្យសុំ Medi-Cal មុនពេលអត្ថប្រយោជន៍ PE សម្រាប់ស្ត្រីមានផ្ទៃពោះ របស់នាងផុតកំណត់ ឬ នៅក្នុងរយៈពេលបីខែបន្ទាប់ពីថ្ងៃទទួលការថែទាំសុខភាពនោះ (<u>មិនមែន</u>ថ្ងៃចុះសំបុត្រទារប្រាក់នោះទេ---ពេលនោះ ប្រហែលហួសពេលហើយ) ។** ឆ្លើយ "ចាំ" ចំពោះសំណួរនៅក្នុងពាក្យសុំ Medi-Cal ស្តីពីចំណាយថែទាំសុខភាពនៅក្នុងរយៈពេលបីខែកន្លងមក សូម្បីតែនាងមិនទាន់ទទួលសំបុត្រទារថ្លៃនៅឡើយក៏ដោយ ។ បើនាងមិនចង់បានកម្មវិធី Medi-Cal បន្ទាប់ពី PE ដោយសារការលូតកូន ឬដោយមូលហេតុណាក៏ដោយ នាងនៅតែគប្បីដាក់ពាក្យហើយគូស "ចាំ" សម្រាប់ការធានារ៉ាប់រង Medi-Cal បីខែនោះ ។ Medi-Cal អាចធានារ៉ាប់រងចំពោះការថែទាំសុខភាព ដែលបានទទួលនៅក្នុងបីខែមុនការដាក់ពាក្យសុំ Medi-Cal ដែលអត្ថប្រយោជន៍ PE សម្រាប់ស្ត្រីមានផ្ទៃពោះ មិនធានារ៉ាប់រងទេ ។

ចុះបើនាងខ្ញុំបង់ថ្លៃសម្រាប់ការថែទាំសុខភាពរួចហើយ តើយ៉ាងម៉េចដែរ?

បន្ទាប់ពីនាងដាក់ពាក្យសុំ ហើយទទួល Medi-Cal រួចហើយ ចូរស្នើសុំអ្នកផ្តល់សេវាថែទាំសុខភាពរបស់នាង ដើម្បីទារថ្លៃនោះពីកម្មវិធី Medi-Cal ហើយសងថ្លៃឱ្យនាង ។ បើអ្នកផ្តល់សេវាថែទាំមិនព្រមទេ ទូរស័ព្ទ ឬសរសេរសំបុត្រទៅកាន់កម្មវិធី Medi-Cal នៅឯទីក្រុង Sacramento ស្តីអំពីកម្មវិធី *Conlan* Beneficiary Reimbursement Program ។

សម្រាប់ការទាមទារថ្លៃថែទាំសុខភាព
Department of Health Care Services
Beneficiary Services
P.O. Box 138008
Sacramento, CA 95813-8008
(916) 403-2007
TDD: (916) 635-6491

សម្រាប់ការទាមទារថ្លៃថែទាំធ្មេញ
Denti-Cal
Beneficiary Services
P.O. Box 526026
Sacramento, CA 95852-6026
(916) 403-2007
TDD: (916) 635-6491

បើនាងចង់ទទួល PE សម្រាប់ស្ត្រីមានផ្ទៃពោះ ឬដើម្បីដាក់ពាក្យសុំ Medi-Cal សូមសួរអ្នកផ្តល់សេវាថែទាំសុខភាពរបស់នាង ។